# សេវាថែទាំធ្មេញ ភ្នែក និងសុខភាពទូទៅ ដោយឥតគិតថ្លៃ

SEATTLE/KING COUNTY CLINIC

## ថ្ងៃទី 23 - 26 ខែ មេសា ឆ្នាំ 2026 នៅមជ្ឈមណ្ឌល Seattle Center







## អំពីគ្លីនិក

- **សំបុត្រចូលមានចំនួនកំណត់ជារៀងរាល់ថ្ងៃ,** ចែកចាយនៅម៉ោង 5:30 ព្រឹក នៅក្នុងអាគារ Fisher Pavilion មជ្ឈមណ្ឌល Seattle Center (200 Thomas St)។
- អ្នកមិនអាចទទួលបានសេវាសុខភាពមាត់ធ្មេញ និងសេវាថែទាំភ្នែកក្នុងថ្ងៃតែមួយឡើយ
- គ្មានការណាត់ជួប ឬការចុះឈ្មោះជាមុនទេ – **ដោយផ្អែកលើអ្នកមកមុនបានមុន**
- **សូមកុំ** ចូលរួមកម្មវិធីនេះ ប្រសិនបើអ្នកមានអាការៈឈឺ ឬមិនស្រួលខ្លួន
- មានផ្តល់ជូនអ្នកបកប្រែភាសា
- មានកន្លែងចតរថយន្តឥតគិតថ្លៃនៅផ្លូវ Mercer St. Garage (650 3rd Ave N)
- **សូមរៀបចំខ្លួនដោយមានម្ហូបអាហារ សម្លៀកបំពាក់សមរម្យ និងថ្នាំលេបប្រចាំថ្ងៃរបស់អ្នកសម្រាប់រយៈពេញមួយថ្ងៃ**

## ស្វាគមន៍អ្នកទាំងអស់គ្នាអាចចូលរួមបាន!

- សម្រាប់អ្នកណា ដែលខ្វះខាត និងពិបាកក្នុងការទទួលបានសេវា និង/ឬមានលទ្ធភាពទទួលបានសេវាថែទាំសុខភាព
- អ្នកជំងឺមិនតម្រូវឱ្យមាន ID ឬ ឬឯកសារណាមួយឡើយ
- អ្នកជំងឺមិនចាំបាច់ទាល់តែជាអ្នករស់នៅក្នុងតំបន់ Seattle ឬ King County ទេ

## សេវាទាំងអស់ឥតគិតថ្លៃ

**ការថែទាំធ្មេញ៖** ការព្យាបាលសម្រាប់ដោះស្រាយការឈឺចាប់ ឬការមិនស្រណុកខ្លួន ធ្មេញពុកដែលគេដឹង ឬសង្ស័យ អញ្ចាញធ្មេញហើម និងធ្មេញបាក់។

**ការថែទាំភ្នែក៖** ការពិនិត្យមើលភ្នែក ការពិនិត្យភ្នែកទាំងមូល វ៉ែនតាដែលវេជ្ជបណ្ឌិតចេញវេជ្ជបញ្ជា។ សូមយកវេជ្ជបញ្ជាដែលបានព្រីនចេញមកជាផ្លូវការ (មានអាយុកាលតិចជាងពីរឆ្នាំ) មកជាមួយ ដើម្បីមិនចាំបាច់ឆ្លងកាត់ការពិនិត្យភ្នែក និងគ្រាន់តែមកទទួលយកនតា។

**វេជ្ជសាស្ត្រ៖** ការថែទាំបឋម ការធ្វើតេស្តក្នុងមន្ទីរពិសោធន៍មួយចំនួនដែលបានជ្រើសរើស ការថតសុដន់ អ៊ុលត្រាសោន ការថតកាំរស្មីអ៊ិច ការចាក់វ៉ាក់សាំង ផ្នែករោគសើស្បែក ការថែទាំជើង ការព្យាបាលដោយចលនា ការចាក់ម្ជុលវិទ្យាសាស្ត្រ ការផ្តល់អាហារូបត្ថម្ភ សុខភាពអាកប្បកិរិយា និងច្រើនទៀត។

**ធនធាននានា៖** ការងារសង្គមកិច្ច ជំនួយក្នុងការទាក់ទងនឹងការធានារ៉ាប់រងសុខភាព និងច្រើនទៀត។


គេហទំព័រ៖
**seattlecenter.org/patients**

អ៊ីមែល៖
**SKCClinic@seattlecenter.org**

លេខទូរសព្ទ៖
**206.684.7200**


ព័ត៌មានបន្ថែម

**មានបន្តទៀត**



### តើខ្ញុំអាចទទួលសេវានៅគ្លីនិកដោយរបៀបណា?

- សូមទៅយកសំបុត្រនៅ នៅអាគារ Fisher Pavilion មជ្ឈមណ្ឌល Seattle Center។ សាល Fisher Pavilion បើកជារៀងរាល់ថ្ងៃ នៅម៉ោង 12:30 AM សម្រាប់អ្នកជំងឺដែលមកដល់មុនគេ (សូមមើលគេហទំព័រ seattlecenter.org/patients សម្រាប់ផែនទី និងព័ត៌មានលម្អិត)។
- មុនពេលចូល អ្នកជំងឺ និងអ្នករួមដំណើររបស់ពួកគេនឹងឆ្លងកាត់ការត្រួតពិនិត្យសុខភាព។ អ្នកដែលមានរោគសញ្ញាដូចជំងឺផ្ដាសាយធំ ឬ COVID នឹងមិនអនុញ្ញាតឱ្យចូលឡើយ។
- សំបុត្រមានកំណត់នឹងត្រូវចាប់ផ្ដើមចែកជារៀងរាល់ថ្ងៃ នៅម៉ោង 5:30 AM។ សំបុត្រនេះ អាចប្រើបានតែក្នុងថ្ងៃនោះប៉ុណ្ណោះ។ ម្នាក់អាចទទួលសំបុត្របានតែមួយសន្លឹក។
- អ្នកជំងឺនឹងត្រូវចូលទៅគ្លីនិកតាមលំដាប់នៃលេខសំបុត្រ។

### តើខ្ញុំគួរត្រៀមលក្ខណៈអ្វីខ្លះ សម្រាប់ការទៅគ្លីនិកនេះ?



- **ដំណើរទៅគ្លីនិកនេះ អាចចំណាយពេលពេញមួយថ្ងៃ។ សូមមកដោយត្រៀមលក្ខណៈជាស្រេច ដើម្បីមើលថែខ្លួនអ្នក។**
- **សូមកុំមក** គ្លីនិក ប្រសិនបើអ្នកមានអារម្មណ៍ថា មានជំងឺ ឬមិនស្រួលខ្លួន។
- សូមនាំយកអាហារ ភេសជ្ជៈ និងថ្នាំពេទ្យណាមួយ ដែលអ្នកចាំបាច់ត្រូវប្រើប្រាស់ពេញមួយថ្ងៃ។
- **សូមកុំ** តមអាហារ មុនពេលធ្វើតេស្តឈាម។
- ដើម្បីទទួលបានការថែទាំធ្មេញ អ្នកត្រូវតែមានសម្ពាធឈាម និងគ្លុយកូស (ជាតិស្ករ) ក្នុងកម្រិតកំណត់ជាក់លាក់ ដើម្បីធានាសុវត្ថិភាព។
- សូមស្លៀកសំលៀកបំពាក់ដែលងាយស្រួល។
- មិនអនុញ្ញាតឱ្យនាំយកសត្វចិញ្ចឹមចូល លើកលែងតែជាសត្វសម្រាប់បម្រើសេវាដែលទទួលបានការហ្វឹកហ្វឺន
- ឪពុកម្ដាយ ឬអាណាព្យាបាលស្របច្បាប់ត្រូវតែអមដំណើរមកជាមួយអ្នកជំងឺ ដែលមានអាយុក្រោម 18 ឆ្នាំ។ អាចមានការលើកលែងចំពោះយុវជន ដែលមានអាយុចាប់ពី 13 ឆ្នាំឡើងទៅ ដែលមិនមានទំនាក់ទំនងជាមួយឪពុកម្ដាយ ឬអាណាព្យាបាលស្របច្បាប់។ អ្នកឯកទេសកុមារអាចនឹងមិនមាន ដើម្បីផ្ដល់ការថែទាំដល់កុមារទេ។



### តើមានអ្នកចេះនិយាយភាសារបស់ខ្ញុំដែរឬទេ?

- នឹងមានអ្នកបកប្រែភាសា ដែលត្រៀមរួចជាស្រេចនៅទូទាំងគ្លីនិក។

### តើមានអ្វីកើតឡើងនៅពេលខ្ញុំចូលក្នុងគ្លីនិក?

- នឹងមានអ្នកជំងឺមកជាច្រើន។ **អ្នកប្រហែលជាមិនអាចទទួលបានសេវាទាំងអស់ ដែលអ្នកចង់បាន ឬដែលផ្ដល់ជូននៅថ្ងៃតែមួយបានទេ។** អ្នកមិនអាចទទួលបានសេវាសុខភាពមាត់ធ្មេញ និងសេវាថែទាំភ្នែកក្នុងថ្ងៃតែមួយឡើយ។
- អ្នកជំងឺអាចតម្រង់ជួររង់ចាំយកសំបុត្រចូលនៅថ្ងៃផ្សេងទៀត ដើម្បីទទួលសេវាថែទាំបន្ថែម។
- អ្នកនឹងទទួលបានបណ្ណសម្រាប់ចូលគ្លីនិកមួយសន្លឹក។ បណ្ណនេះអនុញ្ញាតឱ្យអ្នកចេញទៅក្រៅ ហើយចូលអគារគ្លីនិកវិញបានសម្រាប់តែថ្ងៃនោះប៉ុណ្ណោះ។
- យើងនឹងប្រមូលព័ត៌មានផ្ទាល់ខ្លួនជាមូលដ្ឋាន រួមមាន ឈ្មោះ អាយុ និងអាសយដ្ឋានប្រៃសណីយ៍ ដែលយើងអាចផ្ញើលទ្ធផលតេស្តឈាម និង/ឬវ៉ែនតាដែលបានបញ្ចប់រួច។
- នៅក្នុងកន្លែងផ្ដល់សេវាថែទាំនីមួយៗ (ធ្មេញ ភ្នែក ឬសេវាព្យាបាលទូទៅ) អ្នកនឹងរង់ចាំវេនរបស់អ្នកតាមលំដាប់លំដោយ ហើយនឹងត្រូវបានព្យាបាលតាមលំដាប់អ្នកមកមុនបានមុន (មិនផ្អែកលើលេខសំបុត្រដើមរបស់អ្នកទេ)។
- ប្រសិនបើអ្នកកំពុងតម្រង់ជួរសម្រាប់ការទទួលសេវា ហើយអ្នកចាកចេញពីកន្លែងរបស់អ្នកក្នុងរយៈពេលយូរ នោះអ្នកនឹងបាត់បង់កន្លែងនៅក្នុងជួរ ហើយនឹងត្រូវទៅតម្រង់ជួរនៅខាងចុងវិញ នៅពេលអ្នកត្រឡប់មកវិញ។



Photos © Auston James

### តើមានសេវាអ្វីខ្លះ ដែលគ្លីនិកមិនព្យាបាល?

**ការថែទាំធ្មេញ៖** ស្ពានធ្មេញសិប្បនិម្មិត ការដកធ្មេញស្មុគស្មាញ រួមទាំងធ្មេញទាល់ ធ្មេញសិប្បនិមិត្ត ការដាំធ្មេញ ការពត់ធ្មេញ ការព្យាបាលឬសធ្មេញលើធ្មេញទាល់ ថ្នាំសណ្ដំ ការព្យាបាលធ្មេញឱ្យស។
**សេវាព្យាបាលទូទៅ៖** ការធ្វើកោសល្យវិច័យដោយប្រើសំណាកគំរូជាលិកា, ធ្មេញប្លាស្ទិ៍រ, ការថតស្កេន CT, ការដេរភ្ជាប់/ថ្នេរ, ការចាក់វ៉ាក់សាំងសម្រាប់ក្មេងអាយុក្រោម 18 ឆ្នាំ, ការស្កេន MRI, ការចេញវេជ្ជបញ្ជាថ្មីសម្រាប់ថ្នាំព្យាបាលជំងឺផ្លូវចិត្ត។
**ការថែទាំភ្នែក៖** កែវភ្នែក, វ៉ែនតាការពារកម្ដៅថ្ងៃ។

**ថ្នាំបំបាត់ការឈឺចាប់ Opioids មិនអនុញ្ញាតឱ្យប្រើ ឬចេញវេជ្ជបញ្ជាទេ។**

## PARTNERS INCLUDE

141 Eyewear · Amazon · AMN Healthcare · APTA Washington · Arcora Foundation · Cambia Health Foundation · CISC
Climate Pledge Arena · DCG ONE · Fred Hutchinson Cancer Center · Grousemont Foundation · Gull Industries
International Community Health Services · Kaiser Permanente · King County Medical Society · King County Nurses Association
Lucky Seven Foundation · Mary Mahoney Professional Nurses Organization · National Association of Social Workers
Neighborcare Health · The Norcliffe Foundation · OneSight EssilorLuxottica Foundation · Opticians Association of WA
Optometric Physicians of WA · Philips Healthcare · Project Access Northwest · Public Health – Seattle & King County
Quest Diagnostics · Seattle Center · Seattle Center Foundation · Seattle Department of Neighborhoods · Seattle Housing Authority
Seattle Information Technology · Seattle-King County Dental Society · Seattle Office of Immigrant & Refugee Affairs
Seattle Roots Community Health · Snohomish County Dental Society & Foundation · T-Mobile · Underwood Gartland Development
UW Medicine – Family Medicine · UW School of Dentistry · WA Academy of Eye Physicians and Surgeons
WA Acupuncture and Eastern Medicine Association · WA Dental Hygienists' Association · WA Emergency Nurses Association
WA Healthcare Access Alliance · WA State Dental Association · WA State Department of Health · WA State Medical Association
WA State Nurses Association · WA State Society of Oral and Maxillofacial Surgeons